**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកោះកុង**

សំណុំរឿងរដ្ឋប្បវេណី លេខ ៥៥
ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២០
សាលក្រមរដ្ឋប្បវេណី លេខ ១៥ “ង”
ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២២

# សាលក្រម

## ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តកោះកុង

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ជាអសាធារណៈ

ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោង ៩:០០នាទី ព្រឹក

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកោះកុង

**ក្រឡាបញ្ជី**

លោក [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកោះកុង

**ដើមចោទ៖**

ឈ្មោះ [redacted] **ឈាងហ៊ី** ភេទស្រី អាយុ ៣៩ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន [redacted]។

**អ្នកតំណាងដោយអាណត្តិ៖** មេធាវី [redacted] ជាសមាជិកមេធាវី នៃព្រះរាជាណាចក្រកម្ពុជា និងជាមេធាវីនៃក្រុមមេធាវី [redacted] មានការិយាល័យផ្ទះលេខ ២៦២អា/២៦២បេ [redacted]។

**ចុងចម្លើយ៖**

ឈ្មោះ [redacted] **សុធី** ភេទប្រុស អាយុ ៥៧ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន [redacted]។

**អ្នកតំណាងដោយអាណត្តិ៖** មេធាវី [redacted] ការិយាល័យមេធាវី [redacted]។

## អង្គហេតុ និងចំណុចវិវាទ

### ក-ខ្លឹមសារនៃសាលក្រមដែលគូភាគីទាមទារឲ្យតុលាការចេញ

#### ក-បណ្ដឹងដើម

១-ផ្ដាច់អនីតិសង្វាសពីចុងចម្លើយឈ្មោះ [redacted] សុធី

២-សុំគ្រប់គ្រងផ្ទះ និងដីមួយកន្លែងដែលមានទំហំទទឹង ១៥ម៉ែត្រ x បណ្ដោយ ៤៧ម៉ែត្រ ស្ថិតនៅភូមិស្ទឹងវែង សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ ខេត្តកោះកុង

៣-សុំសិទ្ធិគ្រប់គ្រងកូនចំនួន ២នាក់ រួមមាន៖

- ឈ្មោះ [redacted] សៀវម៉ី ភេទស្រី កើតថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៤
- ឈ្មោះ [redacted] សៀវពី ភេទស្រី កើតថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១២

៤-សុំបែងចែកទ្រព្យសម្បត្តិរួមមាន ដីចំនួន ០៣កន្លែង:

- ដីមួយកន្លែងដែលមានទំហំទទឹង ៣២ម៉ែត្រ x បណ្ដោយ ៥១ម៉ែត្រ ស្ថិតនៅភូមិព្រែកស្វាយ សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ ខេត្តកោះកុង
- ដីមួយកន្លែងដែលមានទំហំផ្ទៃក្រឡា ៥៨២៣ ម៉ែត្រក្រឡា ស្ថិតនៅភូមិព្រែកស្វាយ សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ ខេត្តកោះកុង
- ដីមួយកន្លែងដែលមានទំហំផ្ទៃក្រឡា ៦៥១៦៩ ម៉ែត្រក្រឡា ស្ថិតនៅភូមិបឹងយុនឆាង សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង

៥-សុំទាមទារអាហារកិច្ចចិញ្ចឹមកូន ចំនួន ៥០០ (ប្រាំរយ) ដុល្លារអាមេរិក ក្នុងមួយខែ

៦-សុំបែកចែកបំណុលធនាគារស្ថាបនា ចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិក

#### ខ-បណ្ដឹងតប

១-ផ្ដាច់អនីតិសង្វាសពីចុងចម្លើយនៃបណ្ដឹងតបឈ្មោះ [redacted] លាងហ៊ី ភេទស្រី អាយុ ៣៩ឆ្នាំ

២-ឲ្យដើមចោទនៃបណ្ដឹងតបមានសិទ្ធិអំណាចមេបាលើកូនឈ្មោះ [redacted] សៀវម៉ី ភេទស្រី កើតថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៤ មានសំបុត្រកំណើតលេខ ១៨ ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥។

៣-បែងចែកទ្រព្យរួមប្ដីប្រពន្ធ ដែលមានផ្ទះ និងដីមួយកន្លែង ទំហំប្រហែល ១៥ ម៉ែត្រ x ៤៧ ម៉ែត្រ មានទីតាំងស្ថិតនៅភូមិស្ទឹងវែង សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ ខេត្តកោះកុង ជាពីរចំណែកស្មើៗគ្នា។

៤-ទ្រព្យកម្មសិទ្ធិអវិភាគរវាង ខ្ញុំបាទ ចុងចម្លើយនៃបណ្ដឹងតប លោក [redacted] ទុយ និងលោក [redacted] គឹមគុង ចំនួន ១(មួយ) កន្លែង ដូចខាងក្រោម ៖

- ដីមួយកន្លែងទំហំ ៣២ម៉ែត្រ x ៥១ម៉ែត្រ មានក្បាលដីលេខ ៧៨០ មានទីតាំងស្ថិតនៅភូមិព្រែកស្វាយ សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ ខេត្តកោះកុង មានកិច្ចសន្យាលក់-ទិញ លេខ ២៤៧/០៨ ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ



Scanned with CamScanner

២០០៨ បញ្ជាក់ដោយចៅសង្កាត់ស្ទឹងវែង ដែលជាកម្មសិទ្ធិអវិភាគរវាង ដើមចោទ ចុងចម្លើយ និងតតិយជនឈ្មោះ [redacted] ទុយ និងឈ្មោះ [redacted] គឹមគុង នូវអចលនវត្ថុ ដូចខាងក្រោម៖

- ចំណែករបស់ដើមចោទនៃបណ្តឹងតបចំនួន ១២,៥%
- ចំណែកចុងចម្លើយនៃបណ្តឹងតបចំនួន ១២,៥%
- ចំណែករបស់ម្ចាស់ចំណែកកម្មសិទ្ធិអវិភាគឈ្មោះ [redacted] គឹមគុង ចំនួន ២៥%
- ចំណែករបស់ម្ចាស់ចំណែកកម្មសិទ្ធិអវិភាគឈ្មោះ [redacted] ទុយ ចំនួន ៥០%

៥-ប្រគល់ទ្រព្យសម្បត្តិចំនួន ៣(បី) កន្លែង ដូចខាងក្រោម ទៅឲ្យដើមចោទនៃបណ្តឹងតប ដើម្បីកាន់កាប់ ប្រើប្រាស់ អាស្រ័យផល និងធ្វើជាកម្មសិទ្ធិ៖

- ដីមួយកន្លែងទំហំប្រមាណ ៥៨២៣ ម២ មានក្បាលដីលេខ ៧៨៤ មានទីតាំងស្ថិតនៅភូមិព្រែកស្វាយ សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ ខេត្តកោះកុង។

- ដីមួយកន្លែងទំហំប្រមាណ ១៣២៤៧ ម$^{២}$ មានក្បាលដីលេខ ៧៣៤ មានទីតាំងស្ថិតនៅភូមិព្រែកស្វាយ សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ ខេត្តកោះកុង មានលិខិតបញ្ជាក់លេខ ៩២៣/២០ ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ ២០២០ បញ្ជាក់ដោយចៅសង្កាត់ស្ទឹងវែង។

- ដីមួយកន្លែងទំហំប្រហែល ៦៥១៦៩ ម$^{២}$ មានក្បាលដីលេខ ១៨៦ មានទីតាំងស្ថិតនៅភូមិបឹងយុនធាង សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង មានសលាកបត្រព័ត៌មាន លេខ កក.០០៩៩១៥០ ចុះថ្ងៃទី ០៦ ខែវិច្ឆិកា ឆ្នាំ២០១២ បញ្ជាក់ដោយចៅសង្កាត់ស្មាច់មានជ័យ។

៦-បង្គាប់ឲ្យដើមចោទនៃបណ្តឹងតប និងចុងចម្លើយនៃបណ្តឹងតបមានកាតព្វកិច្ចសហការគ្នាសងបំណុលរួម ដូចខាងក្រោម៖

- ជំពាក់ធនាគារ ស្ថាបនា សរុបចំនួន ២០.០០០ (ពីរម៉ឺន)ដុល្លារអាមេរិក មានកិច្ចព្រមព្រៀងឥណទាន ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៨ និងកិច្ចសន្យាហ៊ីប៉ូតែក ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៨ រួមទាំងតារាងកាលវិភាគបង់ប្រាក់ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៨

- ជំពាក់ថ្លៃសម្ភារៈសំណង់ សម្រាប់សាងសង់ផ្ទះ(ជាន់ទី១)ដែលកំពុងរស់នៅសព្វថ្ងៃ សរុបចំនួន ១៣.០០០ (មួយម៉ឺនបីពាន់)ដុល្លារអាមេរិក

៧-បង្គាប់ឲ្យចុងចម្លើយនៃបណ្តឹងតប សងប្រាក់ដល់ដើមចោទនៃបណ្តឹងតប សរុបចំនួន ១៥.១៨៣.៣៤០ (ដប់ប្រាំលានមួយសែនប៉ែតសិបបីម៉ឺនបីរយសែសិប) រៀល ជាប្រាក់ដែលដើមចោទនៃបណ្តឹងតបបានបង់សងធនាគារជំនួនឲ្យចុងចម្លើយនៃបណ្តឹងតប ចាប់តាំងពីថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ២០១៨ រហូតដល់ខែកុម្ភៈ ឆ្នាំ ២០២១។

៨-បង្គាប់ឲ្យចុងចម្លើយនៃបណ្តឹងតប ប្រគល់ឯកសារពាក់ព័ន្ធនឹងអចលនវត្ថុទាំងអស់ ដែលជាទ្រព្យដោយឡែករបស់ដើមចោទនៃបណ្តឹងតប ទៅឲ្យដើមចោទនៃបណ្តឹងតបវិញ។



Scanned with CamScanner

៩-បង្គាប់ឲ្យដើមចោទនៃបណ្តឹងតប និងចុងចម្លើយនៃបណ្តឹងតប ទទួលបន្ទុកអាហារកិច្ចចិញ្ចឹមកូនរៀងៗខ្លួន។

**ខ-ដំណើររឿងក្តី និងចំណុចវិវាទ**

**១-ការសង្ខេបអំពីរឿងក្តី**

កាលពីអំឡុងឆ្នាំ២០០៤ ដើមចោទឈ្មោះ [redacted] លាងហ៊ី និងចុងចម្លើយឈ្មោះ [redacted] សុធី បានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី ប៉ុន្តែ មិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ឡើយ។ នៅក្នុងអំឡុងពេលរស់នៅជាមួយគ្នា ដើមចោទ និងចុងចម្លើយ ទទួលបានចំណងដៃកូនចំនួន ២នាក់ រួមមានឈ្មោះ [redacted] សៀវម៉ី ភេទស្រី កើតថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ២០០៤ និងឈ្មោះ [redacted] សៀវពី ភេទស្រី កើតថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១២។

ដើមចោទ និងចុងចម្លើយ មានទ្រព្យសម្បត្តិមួយចំនួន ដែលមានឈ្មោះរួមគ្នា រួមមាន ១-អចលនវត្ថុ(ផ្ទះ និងដី) ទំហំ ១៥ម៉ែត្រ X ៤៧ម៉ែត្រ មានទីតាំងស្ថិតនៅភូមិស្ទឹងវែង សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ ខេត្តកោះកុង ២-អចលនវត្ថុ(ដី) ទំហំ ៨១២២ ម៉ែត្រក្រឡា មានទីតាំងស្ថិតនៅភូមិព្រែកស្វាយ សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ ខេត្តកោះកុង មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ 09040302-0784 ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ ៣-អចលនវត្ថុ(ដី) ទំហំ ៧៣៤ ម៉ែត្រក្រឡា មានទីតាំងស្ថិតនៅភូមិព្រែកស្វាយ សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ ខេត្តកោះកុង មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ 09040302-0734 ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ ៤-អចលនវត្ថុ ទំហំ ៦៥១៦៩ ម៉ែត្រក្រឡា មានទីតាំងស្ថិតនៅភូមិបឹងយុនឆាង សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង មានសលាកបត្រព័ត៌មាន លេខ កក.០០៩៩៥០ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១២ បញ្ជាក់ដោយចៅសង្កាត់ស្មាច់មានជ័យ។ ដោយឡែក ទ្រព្យសម្បត្តិដែលមានឈ្មោះ ដើមចោទ ចុងចម្លើយ និងតតិយជនឈ្មោះ [redacted] ទុយ និងឈ្មោះ [redacted] គឹមតុង រួមមាន អចលនវត្ថុទំហំ ៣២ម៉ែត្រ x ៥១ម៉ែត្រ មានក្បាលដីលេខ ៧៨០ មានទីតាំងស្ថិតនៅភូមិព្រែកស្វាយ សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ ខេត្តកោះកុង មានកិច្ចសន្យាលក់-ទិញ លេខ ២៤៧/០៨ ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៨ បញ្ជាក់ដោយចៅសង្កាត់ស្ទឹងវែង។

ដើមចោទ និងចុងចម្លើយ មានបំណុលរួមជំពាក់ធនាគារស្ថាបនា ចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិក យោងតាមកិច្ចព្រមព្រៀងឥណទាន ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៨ និងកិច្ចសន្យាហ៊ីប៉ូតែក ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៨ រវាងធនាគារស្ថាបនា និងដើមចោទ ចុងចម្លើយ។

បន្ទាប់ពីបានរស់នៅជាមួយគ្នាអស់រយៈពេលច្រើនឆ្នាំកន្លងមក ដើមចោទ និងចុងចម្លើយ បានឈានដល់ការរស់នៅមិនចុះសម្រុងគ្នា និងចេះតែមានបញ្ហានៅក្នុងគ្រួសារ ទើបដើមចោទបានដាក់ពាក្យបណ្តឹងមកសាលាដំបូងខេត្តកោះកុង ដើម្បីសុំលែងលះពីចុងចម្លើយ។

**២-ចំណុចវិវាទ**

-ចំណុចវិវាទទី១ ការផ្តាច់អនីតិសង្វាស



Scanned with CamScanner

-ចំណុចវិវាទទី២ ការទាមទារអំណាចមេបាលើកូនឈ្មោះ [redacted] សៀវម៉ី ភេទស្រី កើតថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៤ និងឈ្មោះ [redacted] សៀវពី ភេទស្រី កើតថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១២

-ចំណុចវិវាទទី៣ ការទាមទារទ្រព្យសម្បត្តិ ១.អចលនវត្ថុ(ដី) មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ 09040302-0784 ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ ទំហំ ៨១២២ ម៉ែត្រក្រឡា មានទីតាំងស្ថិតនៅភូមិព្រែកស្វាយ សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ ខេត្តកោះកុង។ ២.អចលនវត្ថុ(ដី) មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ 09040302-0734 ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ ទំហំ ១២២៩២ ម៉ែត្រក្រឡា មានទីតាំងស្ថិតនៅភូមិព្រែកស្វាយ សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ ខេត្តកោះកុង។ ៣.អចលនវត្ថុ(ដី)មានសលាកបត្រព័ត៌មាន លេខ កក.០០៩៩៥០ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១២ បញ្ជាក់ដោយចៅសង្កាត់ស្មាច់មានជ័យ ទំហំ ៦៥១៦៩ ម៉ែត្រក្រឡា មានទីតាំងស្ថិតនៅភូមិបឹងឃុនឆាង សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង ។

-ចំណុចវិវាទទី៤ ការបែងចែកបំណុលជំពាក់សម្ភារៈសំណង់ និងបំណុលដោយឡែក ដែលចុងបណ្តឹងតប ជំពាក់ដើមបណ្តឹងតប។

**គ-អង្គហេតុគ្មានវិវាទ**

-ដើមចោទ និងចុងចម្លើយទទួលស្គាល់ថា អចលនវត្ថុ(ផ្ទះ និងដី) ទំហំ ១៥ម៉ែត្រ X ៤៧ម៉ែត្រ មានទីតាំងស្ថិតនៅភូមិស្ទឹងវែង សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ ខេត្តកោះកុង ជាកម្មសិទ្ធិអវិភាគរវាងដើមចោទ និងចុងចម្លើយ។

-ដើមចោទ និងចុងចម្លើយទទួលស្គាល់ថា អចលនវត្ថុទំហំ ៣២ម៉ែត្រ x ៥១ម៉ែត្រ មានក្បាលដីលេខ ៧៨០ មានទីតាំងស្ថិតនៅភូមិព្រែកស្វាយ សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ ខេត្តកោះកុង មានកិច្ចសន្យាលក់-ទិញ លេខ ២៤៧/០៨ ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៨ បញ្ជាក់ដោយចៅសង្កាត់ស្ទឹងវែង ជាកម្មសិទ្ធិអវិភាគរវាង ដើមចោទ ចុងចម្លើយ និងតតិយជនឈ្មោះ [redacted] ទុយ និងឈ្មោះ [redacted] គីមគុង។

-ដើមចោទ និងចុងចម្លើយទទួលស្គាល់ថា បំណុលធនាគារស្ថាបនា ចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិក ជាបំណុលរួម។

**ចំណុចវិវាទ និងការអះអាងរបស់គូភាគីទាក់ទិននឹងចំណុចវិវាទ**

**ចំណុចវិវាទទី១** ការផ្តាច់អនីតិសង្វាស់

ក-ការថ្លែងការណ៍របស់ដើមចោទឈ្មោះ [redacted] លាងហ៊ី

ខ្លួននៅតែរក្សាការទាមទារ សុំផ្តាច់អនីតិសង្វាសពីចុងចម្លើយ ដូចក្នុងពាក្យបណ្តឹងដដែល ចំពោះមូលហេតុនៃការសុំផ្តាច់អនីតិសង្វាស គឺមាននារាងៗខ្លួន។

ខ-ការថ្លែងការណ៍របស់ចុងចម្លើយឈ្មោះ [redacted] សុជី

ខ្លួនយល់ព្រមលែងលះជាមួយដើមចោទ ដោយសារអស់មនោសញ្ចេតនាជាមួយគាត់ រួមទាំងបញ្ហាផ្សេងៗ។ ខ្លួនសូមរក្សាចម្លើយដែលមានកំណត់ហេតុត្រៀមសម្រាប់ការទាញហេតុផល លើកទី១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១ ទុកនៅដដែល ។



Scanned with CamScanner

**ចំណុចវិវាទទី២** ការទាមទារអំណាចមេបាលើកូនឈ្មោះ [redacted] សៀវម៉ី ភេទស្រី កើតថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៤ និងឈ្មោះ [redacted] សៀវពី ភេទស្រី កើតថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១២

ក-ការថ្លែងការណ៍របស់ដើមចោទ ដោយឈ្មោះ [redacted] លាងហ៊ី

ខ្លួនស្នើសុំឲ្យតុលាការឲ្យកូនរបស់ខ្លួនចេញមកនិយាយថាគេចង់នៅជាមួយអ្នកណា គឺចង់បានចម្លើយចេញពីមាត់កូនផ្ទាល់។ ករណីកូនឆ្លើយថា ព្រមមករស់នៅជាមួយខ្លួន នោះអាហារកិច្ចចិញ្ចឹមកូនខ្លួនសូមទាមទារតាមលទ្ធភាពដែលចុងចម្លើយមាន។

ខ-ការថ្លែងការណ៍របស់ចុងចម្លើយ ដោយឈ្មោះ [redacted] សុធី

ខ្លួនស្នើសុំឲ្យតុលាការសម្រេចទៅតាមច្បាប់ ចំពោះសិទ្ធិចិញ្ចឹមបីបាច់ថែរក្សាកូន រួមទាំងអាហារកិច្ចចិញ្ចឹមកូន ដោយពុំចាំបាច់រង់ចាំការសម្រេចអំពីកូនឡើយ។

**ចំណុចវិវាទទី៣** ការទាមទារទ្រព្យសម្បត្តិ ១.អចលនវត្ថុ(ដី) មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ 09040302-0784 ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ ទំហំ ៨១២២ ម៉ែត្រក្រឡា មានទីតាំងស្ថិតនៅភូមិព្រែកស្វាយ សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ ខេត្តកោះកុង។ ២.អចលនវត្ថុ(ដី) មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ 09040302-0734 ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ ទំហំ ១២២៩២ ម៉ែត្រក្រឡា មានទីតាំងស្ថិតនៅភូមិព្រែកស្វាយ សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ ខេត្តកោះកុង។ ៣.អចលនវត្ថុ(ដី)មានសលាកបត្រព័ត៌មាន លេខ កក.០០៩៩៥០ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១២ បញ្ជាក់ដោយចៅសង្កាត់ស្មាច់មានជ័យ ទំហំ ៦៥១៦៩ ម៉ែត្រក្រឡា មានទីតាំងស្ថិតនៅភូមិបឹងយុនឆាង សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង ។

ក-ការថ្លែងការណ៍របស់ដើមចោទ ដោយដើមចោទឈ្មោះ គុជ លាងហ៊ី និងអ្នកតំណាងដោយអាណត្តិ

ដើមចោទឈ្មោះ [redacted] លាងហ៊ី បានធ្វើសេចក្តីថ្លែងការណ៍ថា ចំពោះទ្រព្យសម្បត្តិដែលខ្លួនដាក់ជូនតុលាការ ប្រសិនវាជាទ្រព្យរួម ខ្លួនស្នើសុំតុលាការសម្រេចបែងចែកជាពីរចំណែកស្មើៗគ្នា ទៅតាមឯកសារដីធ្លីណាដែលមានឈ្មោះរបស់ខ្លួន ដែលខ្លួនបានដាក់ជូនតុលាការដើម្បីពិនិត្យសម្រេច។

អ្នកតំណាងដោយអាណត្តិបានធ្វើសេចក្តីថ្លែងការណ៍បន្ថែមថា ចំពោះដីមួយកន្លែងទំហំប្រមាណ ៨២៣ ម$^២$ មានក្បាលដីលេខ ៧៨៤ មានទីតាំងស្ថិតនៅភូមិព្រែកស្វាយ សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ ខេត្តកោះកុង មួយកន្លែងទៀត ដីមួយកន្លែងទំហំប្រមាណ ១៣២៤៧ ម$^២$ មានក្បាលដីលេខ ៧៣៤ មានទីតាំងស្ថិតនៅភូមិព្រែកស្វាយ សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ ខេត្តកោះកុង មានលិខិតបញ្ជាក់លេខ ៩២៣/២០ ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២០ បញ្ជាក់ដោយចៅសង្កាត់ស្ទឹងវែង មួយកន្លែងទៀតជាដីមួយកន្លែងទំហំប្រហែល ៦៥១៦៩ ម$^២$ មានក្បាលដីលេខ ១៨៦ មានទីតាំងស្ថិតនៅភូមិបឹងយុនឆាង សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង មានសលាកបត្រព័ត៌មានលេខ កក.០០៩៩១៥០ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១២ បញ្ជាក់ដោយចៅសង្កាត់ស្មាច់មានជ័យ និងមួយកន្លែងទៀតដីមានទំហំ ប្រហែលជា ២៦៨០.៩ ម$^២$ ភូមិព្រែកស្វាយ សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ

ខេត្តកោះកុង ដែលមានលិខិតបញ្ជាក់លេខ ៩២៥/២០ ចុះថ្ងៃទី២៣ ខែមេសាឆ្នាំ២០២០ ត្រង់ចំណុចនេះបញ្ជាក់ថា បន្ទាប់ពីបានស្គាល់គ្នាជាមួយចុងចម្លើយរួចមកមុនឆ្នាំ២០០០មក ដើមចោទ និងចុងចម្លើយបានចូលរួមគ្នាក្នុងការចាត់ចែង និងគ្រប់គ្រងដីខាងលើនេះ រហូតដល់ឆ្នាំ២០០៤ទើបមានចំណងអាពាហ៍ពិពាហ៍ និងស្នើសុំបញ្ជាក់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីដែលមានលិខិតបញ្ជាក់លេខ ១៨០ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៤ បន្ទាប់មកនៅឆ្នាំ២០២០ ទើបមានការស្នើសុំបញ្ជាក់បន្ថែមឲ្យមានការគូសបំបែកក្បាលដីតាមលិខិតស្នើសុំបញ្ជាក់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីដែលមានលិខិតបញ្ជាក់ថាជាទ្រព្យរួមរបស់ប្តីប្រពន្ធ។

ខ-ការថ្លែងការណ៍របស់ចុងចម្លើយ ដោយអ្នកតំណាងដោយអាណត្តិ

ដីចំនួនបីកន្លែង គឺចុងចម្លើយបានកាប់កាប់តាំងពីឆ្នាំ១៩៩៦ គឺជាទ្រព្យដោយឡែករបស់កូនក្តី។ ដោយមានលិខិតបញ្ជាក់ពីមេឃុំ។ ក្នុងករណីនេះ ទោះចុងចម្លើយបានដាក់ពាក្យស្នើសុំកាន់កាប់ឆ្នាំ២០០៤មែន ប៉ុន្តែផ្អែកលើសិទ្ធិកាន់កាប់កាលពីឆ្នាំ១៩៩៦។ មានន័យថា ទ្រព្យនេះជាទ្រព្យដោយឡែកដែលចុងចម្លើយមានតាំងពីរៀបអាពាហ៍ពិពាហ៍ជាមួយដើមចោទមកម្លេះ។ ដោយសារដើមចោទទទួលស្គាល់ថា មានការកាន់កាប់មុនឆ្នាំ១៩៩៦ ប៉ុន្តែពេលនោះមិនទាន់មានប័ណ្ណ មានន័យថា ទទួលស្គាល់ការកាន់កាប់លើដីរបស់ចុងចម្លើយ។ រហូតដល់ឆ្នាំ២០០០ ដើមចោទលើកឡើងថា មានការចាត់ចែងទៅលើទ្រព្យនោះ គឺមិនទាន់នោះទេ ពេលនោះដើមចោទមិនទាន់បានស្គាល់ដីនេះទេថា ដីនោះនៅកន្លែងណា រហូតមកដល់ពេលនេះ ដើមចោទនៅតែមិនស្គាល់ដីនេះច្បាស់ រហូតមកដល់ឆ្នាំ២០០៤ ទើបចុងចម្លើយដាក់ពាក្យស្នើសុំកាន់កាប់ដី នៅក្នុងឯកសារនេះ ដើមចោទមិនបានផ្តិតមេដៃនោះទេ។ ទើបតែមកធ្វើប័ណ្ណកម្មសិទ្ធិនៅឆ្នាំ២០១៩ ឬ២០២០នេះទេ ដែលមានឈ្មោះ ដើមចោទមានឈ្មោះ។ បើដូច្នោះមានន័យថា ដីនេះជាទ្រព្យដោយឡែករបស់ចុងចម្លើយតាំងពីមុនមានអាពាហ៍ពិពាហ៍មកម្លេះ។ ដូច្នេះ ទ្រព្យនេះមានប្រភពមកពីការកាន់កាប់ដំបូងដោយចុងចម្លើយ ទោះសុំសិទ្ធិកាន់កាប់ពេលក្រោយក៏ដោយនៅតែជាទ្រព្យដោយឡែកមុនអាពាហ៍ពិពាហ៍។

គ-ការបំភ្លឺរបស់សាក្សី

សាក្សីឈ្មោះ [redacted] សារិន បានឆ្លើយបំភ្លឺថា ចំការជាប់ដីខ្លួនខាងលិច ចំការរបស់ចុងចម្លើយ កាន់កាប់តាំងកាលពីឆ្នាំ១៩៩៦ ។ ដីខ្លួនមានប័ណ្ណរួចហើយ ចេញប័ណ្ណយូរហើយ។ ប័ណ្ណចេញពីចៅសង្កាត់ឈ្មោះ [redacted] វ៉ាន់។ ទៅធ្វើជាមួយគ្នានឹងចុងចម្លើយ ប៉ុន្តែមិនបានចង់ចាំឆ្នាំ។ នៅឆ្នាំ១៩៩៦ ដោយមានការកាប់ឆ្ការជាមួយគ្នា ដោយដីនៅជាប់គ្នា។ ពេលឆ្នាំនោះខ្លួនមិនស្គាល់ឈ្មោះ ដើមចោទនោះទេ ឃើញតែចុងចម្លើយកាប់ឆ្ការតែឯង។

សាក្សីឈ្មោះ [redacted] គឹមថៃ បានឆ្លើយបំភ្លឺថា បំភ្លឺត្រង់ដីនៅស្ទឹងវែង មានទំហំ ២ហិកតា ជាដីរបស់ឈ្មោះ [redacted] សុធី ព្រោះកាលជំនាន់មកនៅកោះកុង ខ្លួនមកស់នៅជាមួយឈ្មោះ [redacted] សុធី ព្រោះគាត់ត្រូវជាពូខ្លួន។ ចូលកាប់ឆ្ការនៅឆ្នាំ១៩៩៩។ ពេលទំនេរខ្លួនតែងទៅកាប់ឆ្ការព្រៃជួយពូខ្លួន ជាមួយមនុស្សបីនាក់ផ្សេងទៀត



Scanned with CamScanner

ពេលចូលទៅកាប់ឆ្ការនោះ ខ្លួនមិនស្គាល់ឈ្មោះ [redacted] លាងហ៊ី ទេ ព្រោះកាលនោះ គាត់មិនទាន់រៀបអាពាហ៍ពិពាហ៍នោះទេ។

សាក្សីឈ្មោះ [redacted] **សម្បត្តិ** បានឆ្លើយបំភ្លឺថា ខ្លួនត្រូវជាអ្នកក្បែរខាងគាត់ ព្រោះដីគាត់ជាប់ខ្លួន។ ឈ្មោះ [redacted] សុធី ទៅកាប់ឆ្ការដីនោះ កាលពីជាងម្ភៃឆ្នាំមុន ស្ថិតនៅភូមិព្រែកស្វាយ។ ដីខ្លួនមិនទាន់មានប្លង់នោះទេ ព្រោះជាប់មានពាក្យបណ្តឹង។

សាក្សីឈ្មោះ [redacted] **ចន្ទាវ័ត្ត** បានឆ្លើយបំភ្លឺថា តាំងពី១៩៩៩ បានផ្ទេរសាលាមកពីស្រែអំបិល មកកោះកុង បានស្គាល់ឈ្មោះ [redacted] សុធី ខ្លួនរស់នៅជិតផ្ទះរបស់គាត់ ពេលនោះ គាត់មានដីចំនួន ពីរកន្លែង។ ខ្លួនដោយសារជាសិស្សគាត់នៅថ្ងៃឈប់សម្រាក់ខ្លួនតែងទៅជួយកាប់ឆ្ការជាមួយគាត់។ ទីមួយដីនៅភូមិស្ទឹងវែងក្រោយចំការខ្លួន និងដីទីពីរនៅ ២៩៧។

អ្នកតំណាងដោយអាណត្តិឲ្យចុងចម្លើយ បានធ្វើសេចក្តីសន្និដ្ឋានថា ផ្អែកតាមអង្គហេតុ អង្គច្បាប់ និងចម្លើយរបស់សាក្សី ព្រមទាំងភស្តុតាងជាឯកសារនានា ឃើញដីបីកន្លែង ដែលមានក្បាលដីលេខ ៧៨៤ មានវិញ្ញាបនបត្រអចលនវត្ថុលេខ០៩០៤០៣០២-០៧៨៤ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ និងក្បាលដីលេខ ៧៣៤ មានទំហំ ១២២៩២ មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ០៩០៤០៣០២-០៧៣៤ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ រួមទាំងក្បាលលេខ ១៨៦ ដែលសលាកបត្រ ព័ត៌មានលេខ កក.០០៩៩៥០ ទី០៦ ខែវិច្ឆិកា ឆ្នាំ២០១២ បញ្ជាក់ចៅសង្កាត់ស្មាច់មានជ័យ គឺជាទ្រព្យដោយឡែករបស់ចុងចម្លើយ។ ដីដែលមានទំហំប្រហែល ១៥ម៉ែត្រ x ៤៧ ម៉ែត្រ មានទីតាំងស្ថិតនៅភូមិស្ទឹងវែង សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ ខេត្តកោះកុង ពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លី លេខ ៣៦១/០៧ ចុះថ្ងៃ១៩ ខែវិច្ឆិកា ឆ្នាំ២០០៧ បញ្ជាក់ដោយមេឃុំស្ទឹងវែង គឺជាទ្រព្យដែលចុងចម្លើយទិញជាមួយដើមចោទ។ ចំពោះទំហំប្រហែល ៣២ ម៉ែត្រ (ទទឹង) ៥១ ម៉ែត្រ (បណ្តោយ) ដែលមានក្បាលដី: ៧៨០ នៅភូមិព្រែកស្វាយ សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ ខេត្តកោះកុង មានលិខិតទិញលក់ លេខ ២៤៧/០៨ ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៨ បញ្ជាក់ដោយឃុំស្ទឹងវែង នៅក្នុងនីតិវិធីត្រៀមសម្រាប់ការហេតុផលលើក១ ដើមចោទធ្លាប់បានឆ្លើយទទួលស្គាល់ថា ជាទ្រព្យកម្មសិទ្ធិអវិភាគ រវាងដើមចោទ ចុងចម្លើយ លោក [redacted] ទុយ និងលោក [redacted] គឹមតុង ផងដែរ។

**ចំណុចវិវាទទី៤** ការបែងចែកបំណុលជំពាក់សម្ភារៈសំណង់ និងបំណុលដោយឡែក ដែលចុងចម្លើយជំពាក់ដើមចោទ

-បំណុលជំពាក់សម្ភារៈសំណង់

ក-ការថ្លែងការណ៍របស់ដើមចោទ ដោយឈ្មោះ [redacted] លាងហ៊ី

ខ្លួនសូមប្រានចោលទាំងស្រុង ពីព្រោះខ្លួនមិនបានដឹងលឺ និងមិនបានពិភាក្សាអ្វីទាំងអស់ជាមួយចុងចម្លើយ។ សំណង់នេះ គឺពុំបានធ្វើដូចការលើកឡើងទេ។ ចំណែកវិក័យប័ត្រ គឺមិនអាចយកជាការបានទេ ព្រោះវិក័យប័ត្រនេះ



Scanned with CamScanner

នរណាក៏អាចសរសេរបានដែរ ដូច្នេះស្នើសុំតុលាការពិនិត្យ ពិចារណាចំពោះវិក័យប័ត្រ ។

ខ-ការថ្លែងការណ៍របស់ចុងចម្លើយ ដោយឈ្មោះ [redacted] សុធី និងអ្នកតំណាងដោយអាណត្តិ

ចំពោះផ្ទះនេះ គឺបានធ្វើថែមឡើងទៅលើមួយជាន់ ក្នុងគោលបំណងជួលឲ្យគេ ប៉ុន្តែបច្ចុប្បន្នសំណង់ផ្ទះខាងលើមិនទាន់សាងសង់រួចហើយទេ។ ដោយសារបំណុលទាំងអស់ដែលបានលើកឡើងខាងលើ សុទ្ធតែខ្ចីដើម្បីយកសាងសង់ផ្ទះ ដើម្បីយកមកផ្គត់ផ្គង់ដល់ជីវភាពគ្រួសារ។ ដូច្នេះដើមចោទ និងចុងចម្លើយត្រូវទទួលខុសត្រូវរួមគ្នាសងបំណុលទាំងអស់ខាងលើ។

-បំណុលដោយឡែក

ក-ការថ្លែងការណ៍របស់ដើមចោទ ដោយឈ្មោះ [redacted] លាងហ៊ី និងអ្នកតំណាងដោយអាណត្តិ

ដើមចោទ [redacted] **លាងហ៊ី** ចំពោះបំណុលធនាគារខ្លួនសូមបែកចែកជាពីរស្មើគ្នា។ ខ្លួនសូមប្រានចោលនូវចំណុចដែលភាគីចុងចម្លើយបានលើកឡើងថា គាត់បានបង់ប្រាក់ធនាគារលើស។

ខ-ការថ្លែងការណ៍របស់ចុងចម្លើយ ដោយឈ្មោះ [redacted] សុធី និងអ្នកតំណាងដោយអាណត្តិ

ពាក់ព័ន្ធនឹងបំណុលធនាគារស្ថាបនាចំនួន ២០.០០០(ពីម៉ឺនដុល្លារ) អាមេរិក គិតចាប់តាំងពីទី០២ ខែកក្កដា ឆ្នាំ២០១៨ រហូតដល់កុម្ភៈ ឆ្នាំ២០២១ គឺដើមចោទ និងចុងចម្លើយ ត្រូវមានកាតព្វកិច្ចសហការសងធនាគារក្នុងម្នាក់ចំនួន ២៩.៦១៦.៦៦០ រៀល។ ប៉ុន្តែជាក់ស្តែងចុងចម្លើយបានបង់សងធនាគារចំនួន ១.៤០០.០០០ (មួយលានបួនសែន) រៀល ជារៀងរាល់ខែ។ ដូច្នេះ សរុបទាំងអស់ចុងចម្លើយបានសងធនាគារលើសដើមចោទសរុបចំនួន ១៥១.៨៣៣.៤០ រៀល ដូច្នេះ ដើមចោទត្រូវទូទាត់មកឲ្យចុងចម្លើយវិញ។

## សំអាងហេតុ

**ចំណុចវិវាទទី១** ការផ្តាច់អនីតិសង្វាស់

១.១-ផ្អែកតាមការសាកសួរសាមីភាគី ឃើញថា ដើមចោទ និងចុងចម្លើយ បានរៀបអាពាហ៍តាមប្រពៃណី ប៉ុន្តែ មិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ឡើយ។ ការរួមរស់នៅជាមួយគ្នារវាងដើមចោទ និងចុងចម្លើយខាងលើនេះ គឺជាអាពាហ៍ពិពាហ៍ក្រៅផ្លូវច្បាប់ ហេតុនេះ ដើមចោទ និងចុងចម្លើយ មិនមានចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ ដើម្បីអាចឲ្យតុលាការពិចារណាអំពីការលែងលះ ស្របតាមបញ្ញត្តិមាត្រា ៩៧៨ និងមាត្រា ៩៧៩ នៃក្រមរដ្ឋប្បវេណីឡើយ។ ផ្ទុយទៅវិញ គូភាគីមានសិទ្ធិសេរីភាពរៀងៗខ្លួនក្នុងការបញ្ឈប់ការរួមរស់ជាមួយគ្នា កាត់ផ្តាច់ទំនាក់ទំនងគ្នា និងអាចមានសហព័ទ្ធរៀងៗខ្លួនបាន ដោយមិនចាំបាច់ប្តឹងលែងលះមកតុលាការឡើយ។

១.២.-យល់ឃើញថា ការទាមទារលែងលះតាមរយៈការផ្តាច់អនីតិសង្វាសនេះ គឺជាការទាមទារដោយខុសច្បាប់ផ្ទុយនឹងបញ្ញត្តិមាត្រា ៧៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ហេតុនេះ គប្បីតុលាការសម្រេចលើកចោលការទាមទារនេះតាមបញ្ញត្តិមាត្រា ៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

**ចំណុចវិវាទទី២** ការទាមទារអំណាចមេបាលើកូនឈ្មោះ [redacted] សៀវម៉ី ភេទស្រី កើតថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៤ និងឈ្មោះ [redacted] សៀវពី ភេទស្រី កើតថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១២



Scanned with CamScanner

១.១-យល់ឃើញថា តាមរយៈសំបុត្រកំណើត លេខ ១៨ នៃសៀវភៅកំណើតលេខ ០១/២០០៥ ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ដោយមន្ត្រីអត្រានុកូលដ្ឋានឃុំស្រែអំបិល និងសំបុត្រកំណើត លេខ ១២៤ នៃសៀវភៅកំណើតលេខ ០២/២០១២ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១២ ដោយមន្ត្រីអត្រានុកូលដ្ឋានសង្កាត់ស្មាច់មានជ័យ ឃើញថា ឈ្មោះ [redacted] សៀវម៉ី ភេទស្រី កើតថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៤ និងឈ្មោះ [redacted] សៀវពី ភេទស្រី កើតថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១២ ពិតជាកូនរវាងដើមចោទ និងចុងចម្លើយ ប្រាកដមែន។

១.២-យល់ឃើញថា ផ្អែកតាមការសាកសួរសាមីភាគី ឃើញថា ដើមចោទបានចង់ឲ្យកូននិយាយដោយផ្ទាល់ថា ព្រមរស់នៅជាមួយឪពុក ឬម្តាយ។ រីឯចុងចម្លើយបានស្នើសុំឲ្យតុលាការសម្រេចតាមច្បាប់ ដោយពុំទាមទារចង់បានការសម្រេចអំពីកូនឡើយ។

១.៣-យល់ឃើញថា ឈ្មោះ [redacted] សៀវម៉ី មានអាយុ ១៧ឆ្នាំ និងឈ្មោះ [redacted] សៀវពី មានអាយុ ១០ឆ្នាំ និងជាក្មេងស្រី។ ដើម្បីឧត្តមប្រយោជន៍របស់កុមារ(ក្មេងស្រី) គប្បីតុលាការសម្រេចឲ្យដើមចោទដែលជាម្តាយជាអ្នកមានអំណាចមេបាលើកូនឈ្មោះ [redacted] សៀវម៉ី ភេទស្រី កើតថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៤ និងឈ្មោះ [redacted] សៀវពី ភេទស្រី កើតថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១២ ដែលជាកូនរវាងដើមចោទ និងចុងចម្លើយ តាមបញ្ញត្តិមាត្រា ១០៣៧ នៃក្រមរដ្ឋប្បវេណី។ ប៉ុន្តែ ភាគីដើមចោទ ត្រូវផ្តល់លទ្ធភាពឲ្យភាគីចុងចម្លើយ ដែលមិនមានអំណាចមេបាលើកូន មានសិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូន។

**ចំណុចវិវាទទី៣** ការទាមទារទ្រព្យសម្បត្តិ ១.អចលនវត្ថុ(ដី) មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ 09040302-0784 ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ ទំហំ ៨១២២ ម៉ែត្រក្រឡា មានទីតាំងស្ថិតនៅភូមិព្រែកស្វាយ សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ ខេត្តកោះកុង។ ២.អចលនវត្ថុ(ដី) មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ 09040302-0734 ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ ទំហំ ១២២៩២ ម៉ែត្រក្រឡា មានទីតាំងស្ថិតនៅភូមិព្រែកស្វាយ សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ ខេត្តកោះកុង។ ៣.អចលនវត្ថុ(ដី)មានសលាកបត្រព័ត៌មាន លេខ កក.០០៩៩៥០ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១២ បញ្ជាក់ដោយចៅសង្កាត់ស្មាច់មានជ័យ ទំហំ ៦៥១៦៩ ម៉ែត្រក្រឡា មានទីតាំងស្ថិតនៅភូមិបឹងយុនធាង សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង ។

១.១-ផ្អែកតាមការសាកសួរសាមីភាគី ឃើញថា ដើមចោទបានធ្វើសេចក្តីថ្លែងការណ៍ថា ចំពោះទ្រព្យសម្បត្តិដែលខ្លួនដាក់ជូនតុលាការប្រសិនវាជាទ្រព្យរួម ខ្លួនស្នើសុំតុលាការសម្រេចបែងចែកជាពីរចំណែកស្មើៗគ្នា ទៅតាមឯកសារដីធ្លីណាដែលមានឈ្មោះរបស់ខ្លួន ដែលខ្លួនបានដាក់ជូនតុលាការដើម្បីពិនិត្យសម្រេច។ ដោយឡែកចុងចម្លើយ បានធ្វើសេចក្តីថ្លែងការណ៍ថា ដីនេះជាទ្រព្យដោយឡែករបស់ចុងចម្លើយតាំងពីមុនមានអាពាហ៍ពិពាហ៍មកម្លេះ។ ដូច្នេះ ទ្រព្យនេះមានប្រភពមកពីការកាន់កាប់ដំបូងដោយចុងចម្លើយ ទោះសុំសិទ្ធិកាន់កាប់ពេលក្រោយក៏ដោយនៅតែជាទ្រព្យដោយឡែកមុនអាពាហ៍ពិពាហ៍ និងស្នើសុំឲ្យតុលាការសម្រេចប្រគល់ទ្រព្យសម្បត្តិចំនួន ៣(បី) កន្លែង នេះ មកឲ្យខ្លួន ដើម្បីកាន់កាប់ ប្រើប្រាស់ អាស្រ័យផល និងធ្វើជាកម្មសិទ្ធិ។



Scanned with CamScanner

១.២-តាមកស្តុតាង ១.ពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លី លេខ ៣៦១/០៧ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧ ២.វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ 09040302-0784 ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ ៣.វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ 09040302-0734 ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកោះកុង និង ៤.សលាកបត្រព័ត៌មាន លេខ កក.០០៩៩៥០ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១២ បញ្ជាក់ដោយចៅសង្កាត់ស្មាច់មានជ័យ ឃើញថា ១.អចលនវត្ថុ(ផ្ទះ និងដី) ទំហំ ១៥ម៉ែត្រ X ៤៧ម៉ែត្រ មានទីតាំងស្ថិតនៅភូមិស្ទឹងវែង សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ ខេត្តកោះកុង។ ២-អចលនវត្ថុ(ដី) មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ 09040302-0784 ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ ទំហំ ៨១២២ ម៉ែត្រក្រឡា មានទីតាំងស្ថិតនៅភូមិព្រែកស្វាយ សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ ខេត្តកោះកុង។ ៣-អចលនវត្ថុ(ដី) មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ 09040302-0734 ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ ទំហំ ១២២៩២ ម៉ែត្រក្រឡា មានទីតាំងស្ថិតនៅភូមិព្រែកស្វាយ សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ ខេត្តកោះកុង។ ៤-អចលនវត្ថុ(ដី) មានសលាកបត្រព័ត៌មាន លេខ កក.០០៩៩៥០ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១២ បញ្ជាក់ដោយចៅសង្កាត់ស្មាច់មានជ័យ ទំហំ ៦៥១៦៩ ម៉ែត្រក្រឡា មានទីតាំងស្ថិតនៅភូមិបឹងយុនធាង សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង។ ជាប្រភេទទ្រព្យកម្មសិទ្ធិអវិភាគ/ទ្រព្យរួមប្តីប្រពន្ធ ដែលមានឈ្មោះ [redacted] លាងហ៊ី និងឈ្មោះ [redacted] សុធី ជាកម្មសិទ្ធិករ/ម្ចាស់សិទ្ធិកាន់កាប់។

១.៣-យល់ឃើញថា ដើមចោទ និងចុងចម្លើយ ពុំមានសំបុត្រអាពាហ៍ពិពាហ៍ ដូចនេះ ដើមចោទ និងចុងចម្លើយ ត្រូវបានចាត់ទុកថា មិនមែនជាសហព័ទ្ធនឹងគ្នាតាមផ្លូវច្បាប់។ ដោយហេតុថា ដើមចោទ និងចុងចម្លើយ បានរស់នៅជាអនីតិសង្វាស ដូច្នេះ ការទាមទារឲ្យបែងចែកទ្រព្យសម្បត្តិរបស់ដើមចោទ និងចុងចម្លើយ ត្រូវផ្អែកតាមបទប្បញ្ញត្តិស្តីពីកម្មសិទ្ធិអវិភាគ តាមបញ្ញត្តិមាត្រា ២០២ និងតាមត្រា ២១២ នៃក្រមរដ្ឋប្បវេណី និងអានុភាពក្នុងការសន្មតនៃការចុះបញ្ជី តាមបញ្ញត្តិមាត្រា ១៣៧ នៃក្រមរដ្ឋប្បវេណី។ តាមបញ្ញត្តិមាត្រា ២០៣ ជាគោលការណ៍ ចំណែកនៃម្ចាស់កម្មសិទ្ធិអវិភាគម្នាក់ៗ ត្រូវបានសន្មតថា ស្មើគ្នា។

១.៤-តាមសំអាងហេតុខាងលើ គប្បីតុលាការសម្រេចបែងចែកទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិអវិភាគដែលមានឈ្មោះដើមចោទ និងចុងចម្លើយ ទៅឲ្យ ដើមចោទឈ្មោះ [redacted] **លាងហ៊ី** និងចុងចម្លើយឈ្មោះ [redacted] **សុធី** ជា **ពីរចំណែកស្មើៗគ្នា** មានដូចខាងក្រោម៖

ក-អចលនវត្ថុ(ផ្ទះ និងដី) ទំហំ ១៥ម៉ែត្រ X ៤៧ម៉ែត្រ មានទីតាំងស្ថិតនៅភូមិស្ទឹងវែង សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ ខេត្តកោះកុង។

ខ-អចលនវត្ថុ(ដី) មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ 09040302-0784 ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ ទំហំ ៨១២២ ម៉ែត្រក្រឡា មានទីតាំងស្ថិតនៅភូមិព្រែកស្វាយ សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ ខេត្តកោះកុង។



Scanned with CamScanner

គ-អចលនវត្ថុ(ដី) មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ 09040302-0734 ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ ទំហំ ១២២៩២ ម៉ែត្រក្រឡា មានទីតាំងស្ថិតនៅភូមិព្រែកស្វាយ សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ ខេត្តកោះកុង។

ឃ-អចលនវត្ថុ(ដី)មានសលាកបត្រព័ត៌មាន លេខ កក.០០៩៩៥០ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១២ បញ្ជាក់ដោយចៅសង្កាត់ស្មាច់មានជ័យ ទំហំ ៦៥១៦៩ ម៉ែត្រក្រឡា មានទីតាំងស្ថិតនៅភូមិបឹងយុនខាង សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង ។

**ចំណុចវិវាទទី៤** ការបែងចែកបំណុលជំពាក់សម្ភារៈសំណង់ និងបំណុលដោយឡែក ដែលចុងចម្លើយជំពាក់ដើមចោទ

១.១-តាមការសាកសួរសាមីភាគី និងភស្តុតាង ឃើញថា ចុងបណ្តឹងតប(ដើមចោទ) បានស្នើសុំប្រានចោលទាំងស្រុង ពីព្រោះខ្លួនមិនបានដឹងលឺ និងមិនបានពិភាក្សាអ្វីទាំងអស់ជាមួយចុងចម្លើយ។ សំណង់នេះ គឺពុំបានធ្វើដូចការលើកឡើងទេ។ ចំណែកវិក័យប័ត្រ គឺមិនអាចយកជាការបានទេ ព្រោះវិក័យប័ត្រនេះនរណាក៏អាចសរសេរបានដែរ ដូច្នេះស្នើសុំតុលាការពិនិត្យ ពិចារណាចំពោះវិក័យប័ត្រ ។ ដោយឡែក ដើមបណ្តឹងតប បានធ្វើសេចក្តីថ្លែងការណ៍ថា ចំពោះផ្ទះនេះ គឺបានធ្វើថែមឡើងទៅលើមួយជាន់ ក្នុងគោលបំណងជួលឲ្យគេ ប៉ុន្តែបច្ចុប្បន្នសំណង់ផ្ទះខាងលើមិនទាន់សាងសង់រួចហើយទេ។ ដោយសារបំណុលទាំងអស់ដែលបានលើកឡើងខាងលើ សុទ្ធតែខ្ចីដើម្បីយកសាងសង់ផ្ទះ ដើម្បីយកមកផ្គត់ផ្គង់ដល់ជីវភាពគ្រួសារ។ ដូច្នេះដើមចោទ និងចុងចម្លើយត្រូវទទួលខុសត្រូវរួមគ្នាសងបំណុលទាំងអស់ខាងលើ។

១.២-តាមការសាកសួរសាមីភាគី និងភស្តុតាង ឃើញថា ដើមចោទ [redacted] **លាងហ៊ី** ចំពោះបំណុលធនាគារខ្លួនសូមបែកចែកជាពីរស្មើគ្នា។ ខ្លួនសូមប្រានចោលនូវចំណុចដែលភាគីចុងចម្លើយបានលើកឡើងថាគាត់បានបង់ប្រាក់ធនាគារលើស តើលើសចំនួនប៉ុន្មាន ហើយខ្លួនបានដាក់ភស្តុតាងជូនលោកចៅក្រមពិនិត្យ។ ចុងចម្លើយបានធ្វើសេចក្តីថ្លែងការណ៍ថា ពាក់ព័ន្ធនឹងបំណុលធនាគារស្ថាបនាចំនួន ២០.០០០ (ពីរម៉ឺនដុល្លារ) អាមេរិកគិតចាប់តាំងពីថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៨ រហូតដល់ខែកុម្ភៈ ឆ្នាំ២០២១ គឺដើមចោទ និងចុងចម្លើយ ត្រូវមានកាតព្វកិច្ចសហការសងធនាគារក្នុងម្នាក់ចំនួន ២៩.៦១៦.៦៦០ រៀល។ ប៉ុន្តែជាក់ស្តែងចុងចម្លើយបានបង់សងធនាគារចំនួន ១.៤០០.០០០ (មួយលានបួនសែន) រៀល ជារៀងរាល់ខែ។ ដូច្នេះ សរុបទាំងអស់ចុងចម្លើយបានសងធនាគារលើសដើមចោទសរុបចំនួន ១៥.១៨៣.៣៤០ រៀល ហេតុដូច្នេះ ដើមចោទត្រូវទូទាត់មកឲ្យចុងចម្លើយវិញ។

១.៣-តាមសំអាងហេតុខាងលើ គប្បីតុលាការទទួលស្គាល់ការអះអាងរបស់ដើមចោទ និងប្រានចោលការទាមទាររបស់ចុងចម្លើយ។

**អំពីប្រាក់ប្រដាប់ក្តី**

ប្រាក់ប្រដាប់ក្តី អនុវត្តតាមបញ្ញត្តិមាត្រា ៦៤ និងមាត្រា ៦៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។



Scanned with CamScanner

# សេចក្តីសម្រេចបញ្ចប់

**១-លើកចោល** ការទាមទារត្រង់ចំណុចទី១ "ការផ្តាច់អនីតិសង្វាស" នៃកម្មវត្ថុពាក្យបណ្តឹង ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ របស់ដើមចោទឈ្មោះ [redacted] លាងហ៊ី។

**២-កំណត់យក** ដើមចោទឈ្មោះ [redacted] **លាងហ៊ី** ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ [redacted] **សៀងម៉ី** ភេទស្រី កើតថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៤ និងឈ្មោះ [redacted] **សៀងពី** ភេទស្រី កើតថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១២ ដែលជាកូនរវាងដើមចោទ និងចុងចម្លើយ។ ចុងចម្លើយឈ្មោះ [redacted] **សុធី** ដែលមិនមានអំណាចមេបាលើកូន មានសិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូន។

**៣-បង្គាប់ឲ្យ**ចុងចម្លើយឈ្មោះ [redacted] **សុធី** បង់សោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីថែរក្សាកូន ចំនួន **៦០០.០០០ (ប្រាំមួយសែន)** រៀល ក្នុង ១ខែ ឲ្យទៅដើមចោទ រហូតដល់ឈ្មោះ [redacted] **សៀងម៉ី** និងឈ្មោះ [redacted] **សៀងពី** ដែលជាកូនរវាងដើមចោទ និងចុងចម្លើយក្លាយទៅជានីតិជន។

**៤**-បែងចែកទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិអវិភាគ ទៅឲ្យដើមចោទឈ្មោះ [redacted] **លាងហ៊ី** និងចុងចម្លើយឈ្មោះ [redacted] **សុធី** ជា **ពីរចំណែកស្មើៗគ្នា** មានដូចខាងក្រោម៖

ក-អចលនវត្ថុ(ផ្ទះ និងដី) ទំហំ ១៥ម៉ែត្រ X ៤៧ម៉ែត្រ មានទីតាំងស្ថិតនៅភូមិស្ទឹងវែង សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ ខេត្តកោះកុង។

ខ-អចលនវត្ថុ(ដី) មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ 09040302-0784 ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ ទំហំ ៨១២២ ម៉ែត្រក្រឡា មានទីតាំងស្ថិតនៅភូមិព្រែកស្វាយ សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ ខេត្តកោះកុង។

គ-អចលនវត្ថុ(ដី) មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ 09040302-0734 ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ ទំហំ ១២២៩២ ម៉ែត្រក្រឡា មានទីតាំងស្ថិតនៅភូមិព្រែកស្វាយ សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ ខេត្តកោះកុង។

ឃ-អចលនវត្ថុ(ដី)មានសលាកបត្រព័ត៌មាន លេខ កក.០០៩៩៥០ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១២ បញ្ជាក់ដោយចៅសង្កាត់ស្មាច់មានជ័យ ទំហំ ៦៥១៦៩ ម៉ែត្រក្រឡា មានទីតាំងស្ថិតនៅភូមិបឹងយុនធាង សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង ។

**៥**-បែងចែកអចលនវត្ថុទំហំ ៣២ម៉ែត្រ x ៥១ម៉ែត្រ មានក្បាលដីលេខ ៧៨០ មានទីតាំងស្ថិតនៅភូមិព្រែកស្វាយ សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ ខេត្តកោះកុង មានកិច្ចសន្យាលក់-ទិញ លេខ ២៤៧/០៨ ចុះថ្ងៃទី ០៦ ខែមីនា ឆ្នាំ២០០៨ បញ្ជាក់ដោយចៅសង្កាត់ស្ទឹងវែង ដែលជាកម្មសិទ្ធិអវិភាគរវាង ដើមចោទ ចុងចម្លើយ និងតតិយជនឈ្មោះ [redacted] ទុយ និងឈ្មោះ [redacted] គីមតុង នូវអចលនវត្ថុ ដូចខាងក្រោម៖



Scanned with CamScanner

-ដើមចោទឈ្មោះ [redacted] លាងហ៊ី ទទួលបានចំណែក ១២,៥%

-ចុងចម្លើយឈ្មោះ [redacted] សុធី ទទួលបានចំណែក ១២,៥%

-ឈ្មោះ [redacted] គីមគុង ទទួលបានចំណែក ២៥%

-ឈ្មោះ [redacted] ទុយ ទទួលបានចំណែក ៥០%

**៦-បង្គាប់**ឲ្យដើមបណ្តឹងតប(ចុងចម្លើយ) និងចុងបណ្តឹងតប(ដើមចោទ)មានកាតព្វកិច្ចសហការគ្នាសងបំណុលធនាគារស្ថាបនា ភីអិលស៊ី សាខាខេត្តកោះកុង ចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិក។

**៧-ច្រានចោល** ការទាមទាររបស់ដើមបណ្តឹងតប(ចុងចម្លើយ) ត្រង់**ចំណុចទី២** "ឲ្យដើមចោទនៃបណ្តឹងតបមានសិទ្ធិអំណាចមេបាលើកូនឈ្មោះ [redacted] សៀវម៉ី" **ចំណុចទី៥** "ប្រគល់ទ្រព្យសម្បត្តិដោយឡែកចំនួន ៣កន្លែងដូចខាងក្រោម ទៅឲ្យដើមចោទនៃបណ្តឹងតប" **ចំណុចទី៦ ត្រង់ទី២** "បំណុលរួមចំនួន ១៣.០០០ ដុល្លារអាមេរិក" **ចំណុចទី៧** "បង្គាប់ឲ្យចុងចម្លើយនៃបណ្តឹងតប សងប្រាក់ដល់ដល់ដើមចោទនៃបណ្តឹងតប ចំនួន ១៥.១៨៣.៣៤០ រៀល" **ចំណុចទី៨** "ឲ្យចុងចម្លើយនៃបណ្តឹងតប ប្រគល់ឯកសារពាក់ព័ន្ធនឹងអចលនវត្ថុទាំងអស់" និង **ចំណុចទី៩** "បង្គាប់ឲ្យដើមចោទនៃបណ្តឹងតប និងចុងចម្លើយនៃបណ្តឹងតប ទទួលបន្ទុកអាហារកិច្ចចិញ្ចឹមកូនរៀងៗខ្លួន"។

**៨**-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ និងចុងចម្លើយ។

សាលក្រមនេះ ប្រកាសជាសាធារណៈ នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២២ ចំពោះមុខដើមចោទ និងចំពោះមុខចុងចម្លើយ។

| **ក្រឡាបញ្ជី** | **ចៅក្រម** |
|---|---|
| ហត្ថលេខា និងត្រា [redacted] | ហត្ថលេខា និងត្រា [redacted] |

---

បានថតចម្លង ត្រឹមត្រូវតាមច្បាប់ដើម

**ថ្ងៃព្រហស្បតិ៍ ១៥រោច ខែអាសាឍ ឆ្នាំខាល ចត្វាស័ក** ព.ស. **២៥៦៦**

**ខេត្តកោះកុង ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២២**

បានឃើញ

**ចៅក្រម**

[redacted]

**ក្រឡាបញ្ជី**

[redacted]